**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ**
នាយកដ្ឋានព័ត៌មាន

# សេចក្តីជូនព័ត៌មាន

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នឹងដឹកនាំគណៈប្រតិភូជាន់ខ្ពស់ អញ្ជើញទៅចូលរួមពិធីតាំងពិព័រណ៍ចិន-អាស៊ាន លើកទី១៤ ពីថ្ងៃទី **១១** ដល់ថ្ងៃទី **១៣ ខែកញ្ញា** ឆ្នាំ**២០១៧** នៅទីក្រុងណាននីង ខេត្តក្វាងស៊ី សាធារណរដ្ឋប្រជាមានិតចិន តបតាមការអញ្ជើញរបស់រដ្ឋាភិបាលចិន ។

គណៈប្រតិភូអមដំណើរ រួមមាន ឯកឧត្តម **ប៉ាន សូរស័ក្តិ** រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ព្រមទាំងឥស្សរៈជនជាន់ខ្ពស់ ដទៃទៀត នៃរាជរដ្ឋាភិបាលកម្ពុជា ។

**សម្តេចតេជោ ហ៊ុន សែន** នឹងអញ្ជើញថ្លែងសុន្ទរកថាក្នុងពិធីបើកការតាំងពិព័រណ៍ចិន-អាស៊ាន លើកទី១៤ ដោយផ្តោតទៅលើការជម្រុញពាណិជ្ជកម្មឱ្យខ្លាំងថែមទៀតរវាងអាស៊ាន និងចិន ព្រមទាំងការទាក់ទាញវិនិយោគិន និងទេសចរចិនមកកាន់តំបន់អាស៊ាន។

បន្ទាប់មក សម្តេចតេជោនឹងអញ្ជើញចូលរួមជាអធិបតីក្នុងពិធីកាត់ខ្សែបូសម្ពោធពន្លាជាតិកម្ពុជា ព្រមទាំងទស្សនាស្តង់តាំងពិព័រណ៍របស់ព្រះរាជាណាចក្រកម្ពុជា និងចូលរួមជាកិត្តិយសក្នុងពិធីសម្ពោធពន្លាជាតិរបស់ប្រទេសប្រ៊ុយណេដារូសាឡាម។

ក្នុងអំឡុងពេលស្នាក់នៅប្រទេសចិន **សម្តេចតេជោ ហ៊ុន សែន** នឹងជួបជាមួយឯកឧត្តម ចាង ការលី ឧបនាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋប្រជាមានិតចិន ហើយនិងទទួលការចូលជួបសម្តែងការគួរសមដោយឡែកពីគ្នា ដោយឯកឧត្តម ចិន វ្វ អភិបាល ខេត្តក្វាងស៊ី និងឯកឧត្តម សុង ថាវ រដ្ឋមន្ត្រីទំនាក់ទំនងអន្តរជាតិ មជ្ឈឹមបក្សកុម្មុយនីស្តចិន។ **សម្តេចតេជោ** ក៏នឹងជួបសំណេះសំណាលជាមួយនិស្សិតកម្ពុជា ដែលកំពុងសិក្សានៅទីក្រុងណាននីង ព្រមទាំងផ្តល់បទសម្ភាសន៍ដល់បណ្តាញសារព័ត៌មានចិន ផងដែរ។

ការតាំងពិព័រណ៍ចិន-អាស៊ាន លើកទី១៤ នេះរំពឹងថា នឹងពង្រឹងថែមទៀតនូវកិច្ចសហប្រតិបត្តិការទ្វេភាគីរវាងប្រទេសសមាជិកអាស៊ាន និងចិន ហើយនិងឈានទៅសម្រេចផែនការបង្កើនពាណិជ្ជកម្ម និងវិនិយោគ ទៅវិញទៅមក ឱ្យដល់ទំហំ១ទ្រីលានដុល្លារអាមេរិក ពីចិនមកកាន់តំបន់អាស៊ាន និង១៥០ពាន់លានដុល្លារអាមេរិក ពីតំបន់អាស៊ានទៅប្រទេសចិន នៅឆ្នាំ២០២០។

រាជធានីភ្នំពេញ, ថ្ងៃទី ០៩ ខែកញ្ញា ឆ្នាំ២០១៧

អាសយដ្ឋាន: លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 214 441, 216 122
ទូរសារ : (855) 23 216 144, 216 141
អ៊ីមែល : mfaic@mfa.gov.kh